ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

**<u>សូមជម្រាបជូន</u>**

**ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**<u>តាមរយៈ</u> : សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**<u>កម្មវត្ថុ</u>** : សំណើចាត់វិធានការដល់អគ្គកុងស៊ុលខ្មែរ ប្រចាំទីក្រុងព្រៃនគរ ឱ្យជួយដោះស្រាយដល់ខ្មែរកម្ពុជាក្រោម។

តាមកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** ជ្រាបថា តាមពត៌មានពីខ្មែរកម្ពុជាក្រោម បានឱ្យដឹងថា ថ្មីៗនេះ នៅឃុំអាង ស្រុកទិនបៀង ខេត្តមាត់ជ្រូក កម្ពុជាក្រោម មានជីកព្រែកមួយខ្សែទទឹង៥០ម៉ែត្រ និងបណ្តោយ១០គីឡូម៉ែត្រ អស់ដីស្រែជាង*៤០០ហិចតា* ក្នុងនោះមានប្រជាពលរដ្ឋ៤០០គ្រួសារ កំពុងប្រឈមមុខនឹងការបាត់បង់ដី។ ការឈឺចាប់ទាំងនោះ មានប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមជាង៤០នាក់ បានតវ៉ាទាមទាររកយុត្តិធម៌។ គួរឱ្យសោកស្តាយដែលអាជ្ញាធរខេត្ត បានបញ្ជាកងកម្លាំង ក្នុងនោះមានទាហានពី៣៣០ ទៅ៣៥០នាក់ និងនគរបាល២៣០នាក់ ព្រមទាំងមានសត្វឆ្កែដ៏កាចសាហាវ៥ក្បាលទៀត បានគំរាមកំហែង និងបង្ក្រាបប្រជាពលរដ្ឋយ៉ាងឃោរឃៅព្រៃផ្សៃជាទីបំផុត។ តាមពត៌មាន នៃការតវ៉ារបស់បងប្អូនខ្មែរដែលជាម្ចាស់ដីធ្លីនោះ មានចំនួនតិចតួច ចំណែកកងកម្លាំងរបស់អាជ្ញាធរមានចំនួនហួសប្រមាណ។ ការសកម្មភាពបែបនេះ សបញ្ជាក់ឱ្យឃើញថា បានរំលោភសិទ្ធិមនុស្ស និងរំលោភយកដីធ្លីពីជនជាតិខ្មែរ ដែលជាម្ចាស់ដើមនៃទឹកដី ហើយពួកគាត់កំពុងប្រឈមមុខនឹងការបាត់បង់ដីធ្លី។ម្យ៉ាងវិញទៀត ពួកគាត់កំពុងទន្ទឹងរង់ចាំការជួយអន្តរាគមន៍ពីរដ្ឋាភិបាលខ្មែរជាបន្ទាន់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** ចាត់វិធានការទៅអគ្គកុងស៊ុលខ្មែរ នៅទីក្រុងព្រៃនគរឱ្យមានការស៊ើបអង្កេត ហើយជួយដោះស្រាយដោយសេចក្តីអនុគ្រោះ ដើម្បីជាឧត្តមប្រយោជន៍នៃជនរួមឈាមខ្មែរយើង។

សូម **ឯកឧត្តម** ទទួលនូវការស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្របំផុត អំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩

**យស្ត ចំរ៉ុ**

**អ្នកតំណាងរាស្ត្រមណ្ឌលបន្ទាយមានជ័យ**

លេខ :..៣៤៥៣..រស

បានឃើញ និងបញ្ជូនមក

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស**

**និងសហប្រតិបត្តិការអន្តរជាតិ**"ដើម្បីមុខការ" ។

ភ្នំពេញ, ថ្ងៃទី..២៣..ខែកញ្ញា ឆ្នាំ២០០៩

**ប្រធានរដ្ឋសភា**

**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**

**<u>ចម្លងជូន</u>**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានរដ្ឋសភា_ព្រឹទ្ធសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ស្ថានទូតនានាប្រចាំកម្ពុជា
- អង្គការសិទ្ធិមនុស្សជាតិ_អន្តរជាតិ
- សារពត៌មានជាតិ_អន្តរជាតិ
- ឯកសារ_កាលប្បវត្តិ